# សិក្ខាសាលាស្តីពី " ការពិនិត្យសមិទ្ធផលក្នុងការអនុវត្តសកម្មភាព ឆ្នាំ ២០២៣ និងការរៀបចំផែនការប្រតិបត្តិសម្រាប់កម្មវិធីបង្ការ ថែទាំ និងព្យាបាលជំងឺអេដស៍ និងជំងឺកាមរោគ ក្នុងវិស័យសុខាភិបាល ឆ្នាំ ២០២៤ "




ដោយមានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តមសាស្ត្រាចារ្យ ឈាង រ៉ា** រដ្ឋមន្ត្រីក្រសួងសុខាភិបាល នៅព្រឹកថ្ងៃពុធ ៨កើត ខែមិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥ ត្រូវនឹងថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២៣ **ឯកឧត្តមសាស្ត្រាចារ្យ ស៊ា ហួង** រដ្ឋលេខាធិការក្រសួងសុខាភិបាល បានអញ្ជើញជាអធិបតីក្នុងពិធីបើកសិក្ខាសាលាស្តីពី " ការពិនិត្យលើសមិទ្ធផលឆ្នាំ២០២៣ និងការរៀបចំផែនការប្រតិបត្តិសម្រាប់កម្មវិធីបង្ការ ថែទាំ និងព្យាបាលជំងឺអេដស៍ និងជំងឺកាមរោគ ក្នុងវិស័យសុខាភិបាល ឆ្នាំ២០២៤ " ដែលរៀបចំឡើងនៅសណ្ឋាគារ សុខាល័យអង្គរ ខេត្តសៀមរាប។ និងមានការចូលរួមផងដែរពីសំណាក់៖

- **ឯកឧត្តមវេជ្ជបណ្ឌិត ទា ផលា** អនុប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
- **លោកសាស្ត្រាចារ្យជំនួយ អ៊ុក វិជ្ជា** ប្រធានមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ
- **ឯកឧត្តមវេជ្ជបណ្ឌិត ក្រុស សារ៉ាត់** ប្រធានមន្ទីរសុខាភិបាល នៃរដ្ឋបាលខេត្តសៀមរាប
- **លោក អ៊ឹង ប៉ូលីន** តំណាងអង្គការ UNAIDS ប្រចាំប្រទេសកម្ពុជា
- **លោកវេជ្ជបណ្ឌិត ដេង សិរង្គា** តំណាងអង្គការ WHO ប្រចាំប្រទេសកម្ពុជា
- **លោកវេជ្ជបណ្ឌិត សុខ ប៊ុណ្ណា** តំណាង PEPFAR ប្រចាំប្រទេសកម្ពុជា






**គោលបំណងនៃសិក្ខាសាលានេះ រួមមាន៖**

១. ពិនិត្យលើសមិទ្ធផល នៃផែនការសកម្មភាពសម្រាប់កម្មវិធីបង្ការ ថែទាំ និងព្យាបាលជំងឺអេដស៍និងកាមរោគក្នុង វិស័យសុខាភិបាល  ដែលបានអនុវត្ត ក្នុងឆ្នាំ២០២៣ និងការសហការជាមួយអង្គការដៃគូ។

២. បច្ចុប្បនភាពគោលការណែនាំ និងនិយាមបែបបទសម្រាប់ អនុវត្ត  កម្មវិធីបង្ការ ថែទាំ និងព្យាបាលជំងឺអេដស៍ និង កាមរោគ ក្នុងឆ្នាំ ២០២៤។

៣. រៀបចំផែន កំណត់សកម្មភាពអាទិភាព និងគោលដៅសម្រាប់អនុវត្តកម្មវិធីបង្ការ ថែទាំ និងព្យាបាលជំងឺអេដស៍ និងកាមរោគក្នុងឆ្នាំ ២០២៤។

៤. ពិនិត្យលើប្រភពថវិកានានា សម្រាប់អនុវត្តកម្មវិធីបង្ការ ថែទាំ និងព្យាបាលជំងឺអេដស៍ និងជំងឺកាមរោគ ឆ្នាំ ២០២៤។

៥. កំណត់សូចនាករ និងគោលដៅ ដោយផ្អែកតាមក្របខ័ណ្ឌតាមដាន និងវាយតម្លៃ (M&E framework) សម្រាប់ កម្មវិធីប្រយុទ្ធនឹងជំងឺអេដស៍ និងជំងឺកាមរោគ ឆ្នាំ២០២៤។



អង្គសិក្ខាសាលានេះ មានការចូលរួមពីសំណាក់តំណាងកម្មវិធីជាតិ (NCHADS, CENAT, NMCHC) MoH-LIT នាយកដ្ឋានផែនការនិងព័ត៌មានសុខាភិបាល មន្ទីរសុខាភិបាលរាជធានី-ខេត្ត កម្មវិធីប្រយុទ្ធនឹងជំងឺអេដស៍រាជធានី-ខេត្ត និងអង្គការដៃគូអភិវឌ្ឍន៍(USAID, US-CDC, UNAIDS, WHO, AHF, CHAI, FHI360/EpiC Project និងដៃគូផ្សេងទៀត) មានចំនួនសរុប ១៩១ នាក់។